# វេទិការវាងសាកលវិទ្យាល័យនិងវិស័យឯកជនលើកទី១ នៅសាកលវិទ្យាល័យខេមតិច

នៅរសៀលថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២២ សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកម្ពុជាបានរៀបចំវេទិកាសាកលវិទ្យាល័យនិងវិស័យឯកជនលើកទី១ក្រោមអធិបតីដោយអ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសេ ស្ថាបនិកនិងជាប្រធានក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យខេមតិច និងជាប្រធានសមាគមសម្ព័ន្ធខ្មែរចិននៅកម្ពុជា និងលោកជំទាវភាព ហៀក ស្ថាបនិកក្រុមហ៊ុនជីប ម៉ុងគ្រុប ។ មានប្រសាសន៍បើកកម្មវិធី អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសេ បានសង្កត់ពីគោលបំណងវេទិកានេះថាជាការប្រឹក្សាយោបល់ទូលំទូលាយ និងពិភាក្សាប្រមូលធាតុចូលដើម្បីរៀបចំកម្មវិធីសិក្សាឱ្យមានស្តង់ដានិងធានាគុណភាពអប់រំដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារនៅកម្ពុជា ទាំងស្ថាប័នរដ្ឋនិងឯកជន។ បន្ថែមពីនេះទៀត វាជាការបង្កើតឱ្យមានក្របខណ្ឌនិងយន្តការជាក់លាក់មួយ ព្រមទាំងបង្កើតបរិយាកាសអំណោយផលលើកិច្ចសហប្រតិបត្តិការ និងភាពជាដៃរវាងសាកលវិទ្យាល័យនិងវិស័យឯកជនផ្តោតលើការអភិវឌ្ឍជំនាញ នវានុវត្តន៍ និងសហគ្រិនភាព។ អ្នកឧកញ៉ាបណ្ឌិត ក៏បានសំណូមពរឱ្យមានការចូលរួម និងគាំទ្របន្ថែមពីវិស័យឯកជន ដើម្បីលើកកម្ពស់ការអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាការអភិវឌ្ឍគ្រឹះស្ថានអប់រំ និងវប្បធម៌ចែករំលែកបទពិសោធន៍ល្អៗក្នុងការជំរុញឱ្យមានភាពរីកចំរើនទាំងអស់គ្នា។

បន្ទាប់ពីមតិថ្លែងសារគន្លិះរបស់អ្នកឧកញ៉ាបណ្ឌិត សាកលវិទ្យាល័យចុះអនុស្សរណៈយោគយល់គ្នារវាងសាកលវិទ្យាល័យខេមតិចនិងដៃគូឧស្សាហកម្ម រួមមាន៖

- ធនាគារកាណាឌីយ៉ា
- ក្រុមហ៊ុនជីប ម៉ុងគ្រុប
- ក្រុមហ៊ុនអាយ អេស អាយ គ្រុប
- មេហ្គា អាសិត មេនិចមេន

អ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសេ ចែកវិញ្ញាបនប័ត្រអាហារូបករណ៍ទេពកោសល្យស្ទែម (STEM Genius Scholarship) ជូនដល់និស្សិតរបស់ខេមតិច។

ជាកិច្ចបញ្ចប់នៃកម្មវិធី អ្នកឧកញ៉ាលៀង ឃុនបានប្រសាសន៍ថាសាកលវិទ្យាខេមតិចជាស្ថាប័នដែល

ផ្តល់នៅការអប់រំឧត្តមសិក្សា ផ្នែកបច្ចេកទេសនិងវិទ្យាសាស្ត្រជាជំនាញចាំបាច់លើគ្រប់វិស័យជាពិសេសវិស័យឯកជន ក៏ជាកាជួយជំរុញលើការលូតលាស់សេដ្ឋកិច្ច និងសង្គមជាតិតរបស់ប្រទេសកម្ពុជា។ អ្នកឧកញ៉ាតែងតែគាំទ្រក្នុងការកែប្រែសហាគមន៍អោយបានល្អ និងចូលរួមក្នុងការផ្លាស់ប្តូរសង្គមជាវិជ្ជមាន ផ្តើមចេញពីការអប់រំនិងអភិចឌ្ឍធនធានមនុស្ស។

កម្មវិធីបានបញ្ចប់ដោយជោគជ័យ និងប្រកបដោយបរិយាកាសស្និតស្នាល។